ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**
លេខ ០៣៥/សសរ អ.ប.ព.
/២៦

# សេចក្តីសម្រេច
# ស្តីពី
# ការទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត
# សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តកែប

## ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អង្គភាពប្រឆាំងអំពើពុករលួយ
- យោងសេចក្តីសម្រេចលេខ ០២៩/២៦ ស.រ អ.ប.ព. ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការបង្កើតក្រុមការងារដឹកនាំ ការងារសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦
- យោងសេចក្តីជូនដំណឹងលេខ ០០៤/២៦ ស.ជ.ណ អ.ប.ព. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការជ្រើសរើស អ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ដែលបានកំណត់អំពីចំនួនអ្នកសង្កេតការណ៍ស្ម័គ្រចិត្តរបស់ អ.ប.ព. នៅតាមរាជធានី-ខេត្តនីមួយៗ អំពីលក្ខខណ្ឌចុះឈ្មោះជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត (មានអាយុចាប់ពី ២១ ឆ្នាំឡើងទៅ - និស្សិត ឬបុគ្គលផ្សេងទៀត ក្រៅពីព្រះសង្ឃ (កំពុងគង់ចាំព្រះវស្សា) គ្រូបង្រៀន មន្ត្រីរាជការសាធារណៈ និងអ្នកសារព័ត៌មាន - មិនត្រូវចូលរួម សង្កេតការណ៍ក្នុងមណ្ឌលប្រឡងដែលមានបងប្អូន សាច់ញាតិ ឬមិត្តភ័ក្តិជាបេក្ខជនប្រឡងដែលនេះជាទំនាស់ ផលប្រយោជន៍ - ត្រូវឬធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល/កិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការងារសង្កេតការណ៍ ការប្រឡង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ - ត្រូវទាញយកកម្មវិធី Angkor Life មកប្រើប្រាស់សម្រាប់ការជូនដំណឹង និង Telegram សម្រាប់ទំនាក់ទំនងការងារសង្កេតការណ៍ - មានមធ្យោបាយ ធនធាន ពេលវេលាគ្រប់គ្រាន់សម្រាប់ បំពេញការងារសង្កេតការណ៍ស្ម័គ្រចិត្តដោយខ្លួនឯង រួមទាំងមធ្យោបាយធ្វើដំណើរ - គោរពតាមច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តជាធរមាន ការចាត់តាំង ដឹកនាំ ប្រគល់ភារកិច្ចរបស់ក្រុមដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់ រាជធានី-ខេត្ត និងថ្នាក់មណ្ឌល ជាពិសេសគោរពបានយ៉ាងខ្ជាប់ខ្ជួនបទប្បញ្ញត្តិ សេចក្តីណែនាំ យល់តួនាទីភារកិច្ច អ្នកសង្កេតការណ៍ស្ម័គ្រចិត្ត និងអំពីលក្ខខណ្ឌសម្រេចជ្រើសរើសបេក្ខជន (អាទិភាពជ្រើសរើសបេក្ខជនដាក់ពាក្យមុន - និស្សិតកំពុងសិក្សាតាមគ្រឹះស្ថានសិក្សានានា - មិនធ្លាប់ចូលរួមសង្កេតការណ៍ - អាទិភាពនារី - មានអាយុច្រើន)
- យោងតម្រូវការចាំបាច់នៃការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ



អគារលេខ ៥៤ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Website: www.acu.gov.kh, E-mail: complaint@acu.gov.kh, info@acu.gov.kh
Tel: 023 223 954, 023 221 653, Hotline: 1282

## សម្រេច

ប្រការ ១._

**ខេត្តកែប** មានអ្នកដាក់ពាក្យជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចំនួន ២៨នាក់ (អ្នកដាក់ពាក្យ)។ សម្រាប់ខេត្តកែប អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) មានគម្រោងជ្រើសរើសអ្នកសង្កេតការណ៍ចំនួន ១៥នាក់ (ហៅថាអ្នកសង្កេតការណ៍)។

ក្នុងចំណោមអ្នកបានដាក់ពាក្យចំនួន ១៥នាក់ មុនគេបំផុត អ.ប.ព. បានពិនិត្យឃើញថា មានអ្នកដាក់ពាក្យ ចំនួន ៥នាក់ ដែលមិនបានបំពេញគ្រប់តាមលក្ខខណ្ឌ ហេតុដូចនេះ អ.ប.ព. ក៏បានពិនិត្យពីលេខរៀង១៦ ដល់ ២០ ក្នុងនោះក៏យើងបានពិនិត្យឃើញថា មិនទាន់គ្រប់លក្ខខណ្ឌ ដូច្នេះយើងបានបន្តពិនិត្យអ្នកបានដាក់ពាក្យទាំងអស់ ដោយទទួលបានអ្នកសង្កេតការណ៍គ្រប់លក្ខខណ្ឌចំនួន ១៥នាក់។

ប្រការ ២._

ទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តកែបចំនួន ១៥នាក់។

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| ១.មណ្ឌល វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ចរិយាវង្ស (ត្បូង) | | | |
| 1 | 1 | នៅ ផល្លុន | ស្រី |
| 2 | 2 | ម៉ាត់ រ៉ូនី | ស្រី |
| 3 | 3 | គីម ស្រីគង | ស្រី |
| 4 | 4 | ហ៊ាង តុលា | ប្រុស |
| 5 | 5 | អឿន ប៊ុនលាប | ប្រុស |
| ២. មណ្ឌល វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ចរិយាវង្ស (ជើង) | | | |
| 6 | 1 | ផុន សម្ផស្ស | ប្រុស |
| 7 | 2 | ឆេង ជូ | ស្រី |

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| 8 | 3 | ម៉ន វិបុល | ប្រុស |
| 9 | 4 | ដៀក ពុធរស្មីដួងច័ន្ទា | ស្រី |
| 10 | 5 | អន ស្រីនាត | ស្រី |
| 11 | 6 | ហ៊ុល រដ្ឋា | ប្រុស |
| 12 | 7 | អឿន ប៊ុន្នី | ស្រី |
| 13 | 8 | សៅ ស្រីនេត | ស្រី |
| 14 | 9 | ហ៊ី ស្រីពេជ | ស្រី |
| 15 | 10 | អ៊ែម វីណា | ស្រី |

ប្រការ ៣._

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តស្ថិតក្រោមការចាត់តាំង ដឹកនាំ និងប្រគល់ភារកិច្ចរបស់ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល។

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តត្រូវបំពេញភារកិច្ចឱ្យបានខ្ជាប់ខ្ជួនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានជាអាទិ៍ឧបសម្ព័ន្ធ២ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ កាតព្វកិច្ច និងវិន័យ អ្នកសង្កេតការណ៍ស្ម័គ្រចិត្តនៃសេចក្តីណែនាំស្តីពីការងារសង្កេតការណ៍របស់អង្គភាពប្រឆាំងអំពើពុករលួយលើដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦។

ប្រការ៤.-

ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល សាមីខ្លួនដូចមានក្នុងប្រការ ២ ខាងលើ និងផ្នែកពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ។

ថ្ងៃពុធ ១២កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២៦

ទេសរដ្ឋមន្ត្រី

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

កិត្តិនីតិកោសលបណ្ឌិត ឱម យ៉ិនទៀង

កន្លែងទទួល៖
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ



អគារលេខ ៥៤ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Website: www.acu.gov.kh, E-mail: complaint@acu.gov.kh, info@acu.gov.kh
Tel: 023 223 954, 023 221 653, Hotline: 1282